# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៥ អនក្រ/បក
### ស្តីពីការផ្ទេរឥណទាន

* * * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីពីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៥ ប្រ.ក.សហវ.ថ. ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីចំណាត់ថ្នាក់ចំណូល និង ចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ ហិរញ្ញវត្ថុសំរាប់គ្រប់គ្រង ឆ្នាំ ១៩៩៥

-បានឃើញច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

-បានឃើញច្បាប់ស្តីពីការបង្កើតគណកម្មាធិការជាតិ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣៩៨/០៤ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ ១៩៩៨

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១៨.០០០ លានរៀល (ដប់ប្រាំបីពាន់លានរៀល) ពីជំពូក ៥០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់កំណត់ មកជំពូក ១៣ ( ចំណាយសកម្មភាពនៃកម្មវិធី ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ សំរាប់ទំពេញនូវតំរូវការចំណាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

**មាត្រា ៣ .**_ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ១៩៩៨ តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៨ ខែឧសភា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ុង ហួត ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២៦ អនក្រ . បក

## ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញា

## កងរាជអាវុធហត្ថ

* * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com